ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០៦

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែមិថុនា ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព | ១ |
| ២- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដារគោលជាតិនៃទម្ងន់ | ៣ |
| ៣- | កិច្ចប្រជុំចង្អៀតលើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ | ៥ |
| ៤- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៦ |
| ៥- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែឧសភា ឆ្នាំ២០១៤ | ១០ |
| ៦- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៧ |

# សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រុមប្រឹក្សាសកម្មភាពជនពិការ។



ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា វិស័យពិការភាពមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ និងទទួលបានសមិទ្ធផលធំធេងជាបន្តបន្ទាប់។ ស្ថានភាពរបស់ជនពិការកម្ពុជាមានភាពល្អប្រសើរឡើងជាលំដាប់។ គោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យពិការត្រូវបានដាក់ឲ្យអនុវត្តប្រកបដោយផ្លែផ្កា។ មជ្ឈដ្ឋានជាតិនិងអន្តរជាតិ និងបងប្អូនជនពិការមានការសប្បាយរីករាយគាំទ្រចំពោះការគិតគូរនិងការយកចិត្តទុកដាក់ខ្ពស់របស់សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា និងអង្គការដៃគូនានាចំពោះសុខមាលភាពជនពិការ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ នេះត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីសម្រេចនូវគោលបំណងសំខាន់ៗចំនួន៥ គឺ ទី១-ធ្វើឲ្យជីវភាពរស់នៅរបស់ជនពិការ និងគ្រួសារមានភាពប្រសើរឡើង គោរពសេចក្តីថ្លៃថ្នូរពីកំណើត និងការរស់នៅដោយឯករាជ្យ ព្រមទាំងសុខមាលភាពពេញលេញ។ ទី២- លើកកម្ពស់ភាពស្មើគ្នាចំពោះមុខច្បាប់ និងការទទួលបានសេវាយុត្តិធម៌ ចាកផុតពីការធ្វើទារុណកម្ម ការរំលោភបំពាន ការកេងប្រវ័ញ្ច អំពើហិង្សា និងដំណោះស្រាយគ្រាមានអាសន្ន ព្រមទាំងលើកស្ទួយសមភាពស្ត្រីពិការ កុមារពិការ និងជនពិការគ្រប់ប្រភេទ។ ទី៣- ផ្តល់សេវាគាំពារសង្គម អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ការងារ អាជីព និងសេវាកម្មនានាជួយជនពិការ។ ទី៤- ផ្តល់សិទ្ធអំណាច

តាមរយៈការចូលរួម ការសម្រេចចិត្ត និងនយោបាយរបស់ជនពិការក្នុងសង្គម។ ទី៥- កែលម្អឱកាសប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនបម្រើជាសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង។



ការរើសអើងដល់ជនពិការនៅក្នុងប្រទេសកម្ពុជាជុំវិញការប្រាស្រ័យទាក់ទងក្នុងដំណើរជីវិតរស់នៅដូចជាការទទួលបានការអប់រំ ការទទួលបានការងារធ្វើ ការទទួលបានសេវាថែទាំវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មកាយសម្បទា និងការគោរពសិទ្ធិនានារបស់ជនពិការមិនទាន់ត្រូវបានលុបចោលទាំងស្រុង ទោះបីជាច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ត្រូវបានដាក់ឲ្យអនុវត្តអស់រយៈពេលប្រាំឆ្នាំមកហើយក៏ដោយ រួមទាំងកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវគោលនយោបាយនិងយុទ្ធសាស្ត្រផ្សេងៗ ក្នុងទិសដៅរួម គឺលើកកម្ពស់សិទ្ធិរបស់ជនពិការ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការភាព២០១៤-២០១៨ ត្រូវបានរៀបចំឡើង ដើម្បីបំពេញចំណុចខ្វះខាត និងបំពេញបន្ថែមលើគោលនយោបាយដែលមានស្រាប់ សំដៅឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗក្នុងកិច្ចខិតខំប្រឹងប្រែងបញ្ចូលជនពិការទៅក្នុងកិច្ចអភិវឌ្ឍសង្គមកម្ពុជានាពេលបច្ចុប្បន្ន[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការកំណត់ស្តង់ដារគោលជាតិនៃទម្ងន់

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆ៊ូច ថោងសេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC)និង ឯកឧត្តម **វ៉ា ពិសី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដារគោលជាតិនៃទម្ងន់ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

ក្រសួងឧស្សាហកម្មនិងសិប្បកម្មបានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដារគោលជាតិនៃទម្ងន់ ដោយអនុលោមតាមមាត្រា ៨ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ។

ដើម្បីធ្វើការអភិវឌ្ឍមូលដ្ឋានគ្រឹះនៃប្រព័ន្ធគ្រប់គ្រងវិស័យមាត្រាសាស្ត្រកម្ពុជាឲ្យទាន់ពេលវេលាដែលកម្ពុជានឹងចូលជាសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចអនុញ្ញាតឲ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិអភិវឌ្ឍឧស្សាហកម្ម និងគោរពតាមលំដាប់ឋានានុក្រមផ្នែកទម្ងន់នៃអង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ(OIML) និងការិយាល័យអន្តរជាតិផ្នែកទម្ងន់និងរង្វាស់រង្វាល់(BIPM) ប្រទេសកម្ពុជាយើងចាំបាច់ត្រូវមានស្តង់ដារគោលជាតិនៃទម្ងន់សម្រាប់ប្រើប្រាស់។ ដូច្នេះទើបអង្គការសហប្រជាជាតិអភិវឌ្ឍឧស្សាហកម្ម(UNIDO) ក្នុងគម្រោងដំណាក់កាលទី១ ពីឆ្នាំ២០០៣-២០០៥ បានផ្តល់កូនទម្ងន់ ១kg ផលិតនៅប្រទេសអាឡឺម៉ង់ ដោយវត្ថុធាតុផ្សំយ៉ាងល្អពីលោហធាតុពិសេសដែលមិនច្រែះចំនួន២គ្រាប់ក្នុងចំណាត់ថ្នាក់ខ្ពស់បំផុត អឺសូន្យ(E0)។ ដោយផ្អែកតាមលក្ខណៈបច្ចេកទេសនិងលក្ខខណ្ឌច្បាប់ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម សម្រេចជ្រើសរើសយកកូនទម្ងន់១គ្រាប់ ដែលមានលេខសម្គាល់ ២៣៤០២០៤ ប្រកបដោយកម្រិតលម្អៀងតូចបំផុតគឺ +0,0៤៥ mg ជាស្តង់ដារគោលជាតិនៃទម្ងន់។

ផលប្រយោជន៍សំខាន់ៗនៃស្តង់ដារគោលជាតិនៃទម្ងន់ចំពោះព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

១.ព្រះរាជាណាចក្រកម្ពុជាយើងជាលើកដំបូងមានស្តង់ដារគោលជាតិនៃទម្ងន់ ជាស្តង់ដារឯកតាមូលដ្ឋានជាតិ។

២.នៅពេលព្រះរាជាណាចក្រកម្ពុជាយើងមានស្តង់ដារគោលជាតិនៃទម្ងន់នេះ ហើយដោយអនុលោមតាមមាត្រា១៣ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ រដ្ឋមន្ត្រីត្រូវចម្លងពីស្តង់ដារគោលជាតិ ដើម្បីប្រកាសជាស្តង់ដារបន្តបន្ទាប់។

៣.តាមរយៈស្តង់ដារបន្តបន្ទាប់ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ(ម.ម.ជ.) អាចបង្កើត និងទទួលស្គាល់ស្តង់ដារប្រតិបត្តិដោយចម្លងតាមលក្ខណៈបច្ចេកទេស សម្ភារៈ រូបរាង ដូចស្តង់ដារបន្ទាប់ ដើម្បីឱ្យមន្ត្រីត្រួតពិនិត្យប្រើប្រាស់សម្រាប់ធ្វើការត្រួតពិនិត្យ និងមានការទទួលខុសត្រូវទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងលក្ខណៈបច្ចេកទេស។

៤.លើសពីនេះទៀត តាមរយៈស្តង់ដារគោលជាតិនៃទម្ងន់នេះ ម.ម.ជ. មានមូលដ្ឋានទទួលបានការទទួលស្គាល់ពីប្រព័ន្ធស្តង់ដារអន្តរជាតិ ISO/IEC 17025 និង 17020 នឹងអាចធ្វើសមាហរកម្មការងារមាត្រសាស្ត្រក្នុងតំបន់និងពិភពលោក។

៥.តាមរយៈ ម.ម.ជ. ដែលទទួលបានការទទួលស្គាល់ពីប្រព័ន្ធស្តង់ដារអន្តរជាតិនេះ ផ្អែកតាមមូលដ្ឋាននៃច្បាប់ស្តីពីមាត្រសាស្ត្រ រាជរដ្ឋាភិបាលនឹងទទួលបានប្រភពចំណូលមិនមែនសារពើពន្ធមួយបន្ថែមទៀតតាមរយៈការផ្តល់សេវាសាធារណៈរបស់ ម.ម.ជ. នៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

៦.តាមរយៈស្តង់ដារគោលជាតិនៃទម្ងន់នេះដែរផលិតផលរបស់កម្ពុជាយើងនឹងបានបញ្ជ្រាបយ៉ាងលឿននឹងបានទាញនូវជំនឿនិងទំនុកចិត្តលើទីផ្សារជាតិនិងអន្តរជាតិ។

៧.ស្តង់ដារគោលជាតិមានតួនាទីដ៏សំខាន់សម្រាប់គ្រប់គ្រងរាល់សកម្មភាព និងសេវាកម្មពាក់ព័ន្ធការងារមាត្រាសាស្ត្រជាអាទិ៍ វិទ្យាសាស្ត្រមាត្រាសាស្ត្រ មាត្រាសាស្ត្រឧស្សាហកម្ម និងនីត្យានុកូលមាត្រាសាស្ត្រ ផ្តល់ភាពយុត្តិធម៌ ភាពជាក់លាក់ ពិតប្រាកដ និងសមធម៌ លើបរិមាណ គុណភាព និងតម្លាភាព ជូនដល់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ធានាឲ្យការប្រើប្រាស់ឧបករណ៍មាត្រសាស្ត្រ (ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់) មានភាពត្រឹមត្រូវសុចរិត ធ្វើឲ្យមានជំនឿ និងទំនុកចិត្ត ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន ហើយលទ្ធផលរិជ្ជមានពីការងារមាត្រសាស្ត្រគឺ មានប្រយោជន៍ដល់គ្រប់សមាសភាពសង្គម រាប់ពីបុគ្គលម្នាក់ៗ គ្រួសារ សហគមន៍ ប្រទេសជាតិនិងអន្តរជាតិផងដែរ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដារគោលជាតិនៃទម្ងន់។

# កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី
# សុខភាពសត្វនិងផលិតកម្មសត្វ

ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) បានដឹកនាំអង្គប្រជុំចង្អៀតលើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិង ផលិតកម្មសត្វ(មាត្រា ៨,៣៩,៤១,៥៩,៦០និង៩៥) នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានវត្តមានតំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម តំណាងក្រសួងពាណិជ្ជកម្ម តំណាងក្រសួងសុខាភិបាល តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងសមាជិក ECOSOCC ចំនួន ០៤រូប។ កិច្ចប្រជុំនេះបានប្រព្រឹត្ត ទៅអស់រយៈពេលបួនថ្ងៃគឺចាប់ពីថ្ងៃទី០៥, ២១, ២៦ ខែឧសភា ឆ្នាំ២០១៤ និងថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៤ ហើយអង្គប្រជុំបានពិភាក្សាស៊ីជម្រៅយ៉ាងផុលផុស ព្រមទាំងចំណាយពេលយ៉ាងយូរ បានលទ្ធផលដូចខាង ក្រោម៖



១- មាត្រាដែលអង្គប្រជុំបានឯកភាពមាន៖
- មាត្រា៣៩ (ជំពូកទី៦ ស្តីពីបសុឱសថ)
- មាត្រា៦០ (ជំពូកទី៩ ស្តីពីចរាចរណ៍សត្វនិងផលិតផលសត្វ)
- មាត្រា៩៥ (ជំពូកទី១៨ ស្តីពីការត្រួតពិនិត្យអនាម័យ)

២- មាត្រាដែលអង្គប្រជុំមិនទាន់បានឯកភាពមាន៖



- មាត្រា៨ (ជំពូកទី៣ ស្តីពីការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតផលសត្វ)
- មាត្រា៤១ (ជំពូកទី៧ ស្តីពីចំណីសត្វ)
- មាត្រា៥៩ (ជំពូកទី៩ ស្តីពីចរាចរណ៍សត្វនិងផលិតផលសត្វ)

ចំពោះ មាត្រា៨ មាត្រា៤១ និងមាត្រា៥៩ ខាងលើ អង្គប្រជុំបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាសារចុះ សារឡើងជាច្រើនពេល ប៉ុន្តែក្រសួងសាមី និងក្រសួងពាក់ព័ន្ធ នៅតែរក្សាជំហររៀងៗខ្លួន។ ដោយមានការយល់ព្រមពីក្រសួងសាមី និងក្រសួងពាក់ព័ន្ធ អង្គប្រជុំសម្រេចរក្សាទុកមាត្រាទាំងបីនេះ ជូនអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ដោយអញ្ជើញ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាមី និងក្រសួងពាក់ព័ន្ធចូលរួមប្រជុំ ក្រោមអធិបតី ភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសម្របសម្រួល។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃអង្គារ ទី១០ ខែមិថុនា ឆ្នាំ២០១៤ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្ដីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល។

២- សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីឯកសណ្ឋាន សញ្ញាសក្ដិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រ។

៣- បញ្ហាផ្សេងៗ

៣.១- ពិធីសារណាហ្គូយ៉ា ស្ដីពីសិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌ នៃអនុសញ្ញាសហប្រជាជាតិ ស្ដីពីជីវៈចម្រុះ។

៣.២- កិច្ចព្រមព្រៀងស្ដីពីសហប្រតិបត្តិការវប្បធម៌ រវាងរដ្ឋាភិបាល នៃរដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី។



ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្ដូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

១-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិល៖

អង្គប្រជុំបានឯកភាពលើទម្រង់ និងខ្លឹមសាររួមរបស់សេចក្ដីព្រាងអនុក្រឹត្យនេះ ដោយមានការបន្ថែមមួយមាត្រា (មាត្រា១២ថ្មី) ឃ្លា កែសម្រួល និងបន្ថែមសមាសភាពរបស់អង្គភាពនៅក្នុងមាត្រាមួយចំនួនដូចខាងក្រោម៖

ជំពូកទី២

-មាត្រា៦ បន្ថែមសមាសភាពចំនួនពីររូប នៅត្រង់ទី១៧ថ្មី និង១៨ថ្មី រដ្ឋលេខាធិការក្រសួងសាធារណៈការនិងដឹកជញ្ជូន និងមេបញ្ជាការកងទ័ពជើងគោក ជាសមាជិក។

-មាត្រា៨ សាមីក្រសួងសុំលប់ត្រង់ទី៣ចេញ ព្រោះតួនាទីនឹងភារកិច្ច នេះមានចែងរួចហើយនៅក្នុងអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

ជំពូកទី៤

-មាត្រា១១ លុបពាក្យ "និងតម្រួតអាកាសយានដ្ឋានមូលដ្ឋាន" នៅពីក្រោយពាក្យ តម្រួតអាកាសយានដ្ឋានអន្តរជាតិ។ បន្ថែមសមាសភាពមួយរូបគឺ អគ្គស្នងការរងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ជាសមាជិក។

-មាត្រា១២ថ្មី តម្រួតអាកាសយានដ្ឋានមូលដ្ឋានជាសេនាធិការនៃ គ.ជ.ស.អ. ដែលមានសមាសភាពដូចខាងក្រោម ៖

- តំណាងគណៈបញ្ជាការខេត្ត .......... ប្រធាន
- នាយកអាកាសយានដ្ឋានមូលដ្ឋាន .......... អនុប្រធាន
- តំណាងស្នងការនគបាលខេត្ត .......... សមាជិក
- តំណាងកងរាជអាវុធហត្ថខេត្ត .......... សមាជិក

ជំពូកទី៦

-មាត្រា១៥៖ បន្ថែមត្រទី១០ថ្មីៈ រៀបចំឲ្យមានសកម្មភាពល្បាតត្រួតពិនិត្យជាចំបារដើម្បីទប់ស្កាត់អំពើភេរវកម្មនិងសកម្មភាពល្មើសច្បាប់ផ្សេងៗ។ និងលប់កឋាខ័ណ្ឌចុងក្រោយ។ (ឧបសម្ព័ន្ធដែលភ្ជាប់អនុក្រឹត្យលុបចេញ)

- មាត្រា១៨ លុបកឋាខ័ណ្ឌចុងក្រោយ។ (ឧបសម្ព័ន្ធដែលភ្ជាប់អនុក្រឹត្យលុបចេញ)

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ស្នើសុំឲ្យលុបឧបសម្ព័ន្ធនៃសេចក្តីព្រាងអនុក្រឹត្យនេះ។

២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រ៖ អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងអនុក្រឹត្យនេះ។

៣- បញ្ហាផ្សេងៗ

៣.១-ពិធីសារណាហ្គូយ៉ា ស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌ នៃអនុសញ្ញាសហប្រជាជាតិ ស្តីពីជីវៈចម្រុះ។

អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសារស្តីពីពិធីសារណាហ្គូយ៉ា ស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌ នៃអនុសញ្ញាសហប្រជាជាតិ ស្តីពីជីវៈចម្រុះ។

៣.២-កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការវប្បធម៌ រវាងរដ្ឋាភិបាល នៃរដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី។

អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសារស្តីពីកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការវប្បធម៌ រវាងរដ្ឋាភិបាល នៃរដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង រដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះ នៅវេលាម៉ោង ១:១៥នាទី។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃអង្គារ ទី២៥ ខែមិថុនា ឆ្នាំ២០១៤ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្ដីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

២- សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម។

៣- សេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីវិស័យវប្បធម៌។

៤- សេចក្ដីព្រាផែនការយុទ្ធសាស្ត្រជាតិ ស្ដីពីពិការភាព ២០១៤-២០១៨ ។

៥- បញ្ហាផ្សេងៗ។

ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្ដូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖



១-សេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម៖

អង្គប្រជុំបានពិនិត្យសេចក្ដីព្រាងច្បាប់ថ្មីដែលរៀបចំដោយក្រុមប្រឹក្សាអ្នកច្បាប់។

តំណាងក្រសួងរ៉ែ និងថាមពល (លោកជំទាវ **ម៉ែន ឆដា**) មានមតិលើមាត្រា៣ថ្មីដោយស្នើសុំដកចេញនូវចំណុច៤ (ផ្នែកផលិតផលពីរ៉ែអលោហៈ) និងចំណុច៥ (ផ្នែកលោហៈមូលដ្ឋាន) ព្រោះថាចំណុចទាំង២នេះជាភារកិច្ចរបស់ក្រសួងរ៉ែនិងថាមពល។

ឯកឧត្តមប្រធានអង្គប្រជុំ បានសម្រេចរក្សាទុកចំណុចទាំង២នេះនៅដដែលសិន យើងមិនកែឯកសារចាស់ទេយើងគ្រាន់តែកែពាក្យ "ឧស្សាហកម្ម រ៉ែនិងថាមពល" ទៅជាពាក្យ "ឧស្សាហកម្មនិងសិប្បកម្ម" ។ ក្រសួងរ៉ែនិងថាមពល អាចលើកស្នើដោយឡែក។

ឯកឧត្តម **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានលើកយកមាត្រា២៤ថ្មី,៤៥ថ្មី ដាក់ជូនអង្គប្រជុំពិនិត្យពិចារណានិងកែសម្រួល។

អង្គប្រជុំបានកែសម្រួល : មាត្រា២៤ថ្មី : ពាក្យ "មិនអាចជួល" ទៅជា "មិនត្រូវបានជួល"
: មាត្រា៤៥ថ្មី : ពាក្យ "ទទួលសំណង" ទៅជា "ទទួលសង"

ទន្ទឹមនោះ ឯកឧត្តម ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានស្នើកែពាក្យក្នុងមាត្រា១៨ថ្មី,មាត្រា៣៧ថ្មី,មាត្រា៣៩ថ្មី,មាត្រា៤១ថ្មី,មាត្រា៤៣ថ្មី,មាត្រា៤៥ថ្មី,មាត្រា៤៦ថ្មី,មាត្រា៤៩ថ្មី។

អង្គប្រជុំបានឯកភាពតាមសំណើកែសម្រួលរបស់ ឯកឧត្តម ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

២- សេចក្តីព្រាងព្រះរាក្រឹត្យ ស្តីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម៖

អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងព្រះរាជក្រឹត្យនេះ។

៣- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីវិស័យវប្បធម៌ ៖

ក-លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ស្នើឲ្យយកឃ្លាទី៤នៃសេចក្តីផ្តើម៖ "ទន្ទឹមនិងនេះក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យវប្បធម៌ត្រូវដកស្រង់បទពិសោធចេញពីគម្រោងសហ-ប្រតិបត្តិការអន្តរជាតិនានា ជាពិសេសកិច្ចសហប្រតិបត្តិការអន្តរជាតិដែលបាននិងកំពុងអនុវត្តក្នុងក្របខ័ណ្ឌដែលជាលទ្ធផលនៃការចុះបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ជាសម្បត្តិបេតិកភណ្ឌពិភពលោក"។

អង្គប្រជុំបានសម្រេចតាមសំណើ។

ខ-លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានស្នើសុំឲ្យមានចង្អុលក្រសួងចាំបាច់ជាអ្នកទទួលខុសត្រូវនៅចំណុចទី៥.១ ការបង្កើតយន្តការ។

អង្គប្រជុំបានសម្រេចទុកដដែល ពីព្រោះនេះជាយន្តការប៉ុណ្ណោះ។ ម៉្យាងទៀតវិស័យវប្បធម៌មិនអាចមានតែក្រសួងមួយអនុវត្តបានទេ វាត្រូវមានក្រសួងស្ថាប័នពាក់ព័ន្ធនិងវិស័យជាច្រើនទៀតជាអ្នកអនុវត្តគោលនយោបាយនេះ។ យន្តការចាស់ដែលមានស្រាប់ដើម្បីដឹកនាំគ្រប់គ្រងលើវិស័យវប្បធម៌នេះរួមមានអាជ្ញាធរអប្សរាដឹកនាំនិងគ្រប់គ្រងតំបន់អង្គរ និងប្រាសាទកោះកេ អាជ្ញាធរព្រះវិហារដឹកនាំនិងគ្រប់គ្រងប្រាសាទព្រះវិហារ។ ក្រៅពីនេះគឺក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ទៅថ្ងៃមុខទៀតអាចនិងមានបង្កើតយន្តការថ្មីចាំបាច់ដើម្បីគ្រប់គ្រងប្រាសាទផ្សេងៗទៀត។

គ-ចំណុច៥.៣ ការគាំទ្រផ្នែកហិរញ្ញវត្ថុ

អង្គប្រជុំបានកែសម្រួលដូចតទៅ :

ដើម្បីអនុវត្តសកម្មភាពក្នុងគោលនយោបាយស្តីពីវិស័យវប្បធម៌ ត្រូវប្រើប្រាស់ថវិកា របស់ក្រសួងស្ថាប័នពាក់ព័ន្ធនិងវិស័យវប្បធម៌ ជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ ជំនួយសប្បុរស និងថវិកាបានមកពីប្រភពផ្សេងៗទៀត។

៤- សេចក្តីព្រាផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៤-២០១៨ ៖

អង្គប្រជុំបានឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិនេះ។

៥- បញ្ហាផ្សេងៗ ៖

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះ នៅវេលាម៉ោង ១:១៥នាទី។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែឧសភា ឆ្នាំ២០១៤*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និវប្បធម៌កម្ពុជា**ប្រចាំខែឧសភា ឆ្នាំ**២០១៤នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុនឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិកសមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភា ឆ្នាំ២០១៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៣% ធៀបនឹងខែមុន និងកើនឡើង ៤,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុន សម្រាប់ក្រុមទំនិញនិងមុខទំនិញសំខាន់ៗ

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ការសិក្សា : | +៨,៣% | ឧស្ម័ន : | +១៣,៧% |
| ភោជនីយដ្ឋាន : | +៨,២% | ផ្លែឈើ : | +១០,៨% |
| គ្រឿងសង្ហារិមនិងសម្ភារៈ | +៧,៧% | សាច់ជ្រូក : | +៩,៧% |
| ប្រើប្រាស់ : | +៦,៩% | ត្រីស្រស់ : | +៧,១% |
| សុខាភិបាល : | +៥,១% | សាច់គោស្រស់ : | +៦,១% |
| ម្ហូបអាហារ : | | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១២–២០១៤

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា[P] | កក្កដា[P] | សីហា[P] | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៨% | ៥,៣% | ៥,៣% | | | | | |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ១,៥% | ០,៤ | | | | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |
| ២០១២ | ដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | មុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០% | ១,១% | ០,២% | -០,២% | -០,២% | ០% | |

**P:** តួលេខខែ មិថុនា កក្កដា និងសីហា ឆ្នាំ២០១៤ ជាតួលេខព្យាករដោយក.ស.វ. ( តាមវិធីសាស្ត្រ **DECOMPOSITION)**

ក្រាហ្វ ១.១. ចលនា និងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣. អត្រាប្តូរប្រាក់

| ប្រភេទ | ឧសភា ២០១៤ | មេសា ២០១៤ | ឧសភា ២០១៣ | ប្រភេទ | ឧសភា ២០១៤ | មេសា ២០១៤ | ឧសភា ២០១៣ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣២៛/១$ | ៤០១៥៛/១$ | ៤០៦៥៛/១$ | **បាត/ដុល្លារ** | ៣២,៧៩បាត/១$ | ៣២,២៥បាត/១$ | ៣០,១០បាត/១$ |
| **៛/បាត** | ១២៣៛/១បាត | ១២៥៛/១បាត | ១៣៥៛/១បាត | **ដុង/ដុល្លារ** | ២១១៤០ដុង/១$ | ២១០៦០ដុង/១$ | ២០៩៨០ដុង/១$ |
| **៛/ដុង** | ០,១៩១៛/១ដុង | ០,១៩១៛/១ដុង | ០,១៩៤៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែឧសភា ឆ្នាំ ២០១៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៧៧៧,៨ពាន់លានរៀល (មធ្យមប្រចាំខែ ៩៦% នៃផែនការ) ក្នុងនោះ ចំណូលចរន្តចំនួន ៧៧៣,៦ពាន់លានរៀល (មធ្យមប្រចាំខែ ១០០% នៃផែនការ) និងចំណូលមូលធន ៤,២ពាន់លានរៀល។

- បើធៀបនឹងខែមុនចំណូលថវិកាជាតិ ថយចុះ២៨,១% និង ថយចុះ៩,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
- នៅក្នុងចំណូលចរន្ត :
  - ✓ ចំណូលសារពើពន្ធមានចំនួន ៦៧៦,២ពាន់លានរៀល ថយចុះ២៧,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១២,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១២–២០១៤ (ពាន់លានរៀល)



✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៩៧,៤ពាន់លានរៀល កើនឡើង៤៧៣,៣% ធៀបនឹងខែមុន និងកើនឡើង៥៦,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : +៤,៩% | (+២២,១%) | ➢ នេសាទ: -១០០% | (-១០០%) |
| ➢ ចំណូលពន្ធដារ : -៣៦,៨% | (+២៥,៥%) | ➢ រុក្ខាប្រមាញ់ : -១០០% | (-១០០%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +២២,៥% | (+៤៣,០%) | ➢ សម្បទានរ៉ែ : +៦៤១% | (+៧១០%) |
| ✧ កាស៊ីណូ : -៤,៨% | (+៤៦,៨%) | ➢ អាកាសចរណ៍ស៊ីវិល : -១០០% | (-១០០%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +៣៤១១% | (+១២៨៨%) | ➢ ផលទុននៃសកម្មភាពទេសចរណ៍: +៤០៣២២១% | (+១១៦%) |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: +៣,៦% | (+៣,៣%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +១១៨,៨% | (+២០៦,៥%) |
| | | ➢ អាករស្ពានទូត (លិខិតឆ្លងដែន និងទិដ្ឋាការ): +៧,៩% | (+២៣,៧%) |
| | | ➢ ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ : +១១១,០% | (+២៥៣,៦%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៣៧៨,៣ពាន់លានរៀល (*មធ្យមប្រចាំខែ ៤៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ២៥០,៩ពាន់លានរៀល (*មធ្យមប្រចាំខែ ៦៥% នៃផែនការ*) និងចំណាយមូលធនចំនួន ១២៧,៥ ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* ចំណាយថវិកាជាតិ ថយចុះ ៤៣.៦% និងថយចុះ ៤៧,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តថយចុះ៥៦,១% ធៀបនឹងខែមុន និងថយចុះ៥៨,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេក ចំនួន **៣៩៩,៥** ពាន់លានរៀល ។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១២ –២០១៤ (ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភា ឆ្នាំ២០១៤ មានលក្ខណៈដូចខាងក្រោម:

➢ រូបិយវត្ថុ $M_2$ មានចំនួន ៣៦៤៥៩ពាន់លានរៀល កើនឡើង១,៥% ធៀបនឹងខែមុន និងកើនឡើង ១៥,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **កំណើន $M_2$** ជារួម បណ្តាលមកពីកំណើននៃប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ និងប្រាក់បញ្ញើជារូបិយបណ្ណ។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ មានចំនួន ១៧,២% និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨២,៨% នៃរូបិយវត្ថុ $M_2$ ។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែឧសភា ឆ្នាំ២០១៤



តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៤

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៧% | ១៨,០% | ១៧,៧% | ១៧,៦% | ១៧,២% | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៤% | ១៣,៥% | ១៣,៨% | ១៣,៨% | ១៣,២% | | | | | | | |

ក្រាហ្វ៣.២. បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែឧសភា២០១៤: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន ៣៧៦៦លានដុល្លារថយចុះ០,៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១១៧៥១ ពាន់លានរៀល កើនឡើង ២,៩% ធៀបនឹងខែមុន និងកើនឡើង១៤,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២. ការផ្តល់ឥណទាន និងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *ឧសភា ២០១៤* | *មេសា ២០១៤* | *ឧសភា ២០១៣* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ (ពាន់លានរៀល) | ៣២១៧០ | ៣១៣២៥ | ២៦១១០ |
| ក្នុងនោះ ជារៀល | មិនទាន់មានតួលេខ | ៤៤៧ | ៤១៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ពាន់លានរៀល) | មិនទាន់មានតួលេខ | ៦១៧៦ | ៤១១៨ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៨% | ៥,៩៦% | ៥,៩៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,០២% | ១៥,៩៩% | ១១,៨៤% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៧% | ៤,២៨% | ៤,៤១% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥៤% | ១១,២៧% | ១១,៧៦% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែឧសភាឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

➢**កសិកម្ម** :

✓ នេសាទសម្រេចបាន ៤៣ពាន់តោន កើនឡើង២% ធៀបនឹងខែមុន ប៉ុន្តែថយចុះ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម** :

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា (មិនទាន់មានតួលេខ)

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើង (មិនទាន់មានតួលេខ)

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន –ឧសភា ២០១៤* | *ចំនួន–មេសា ២០១៤* | *ចំនួន–ឧសភា ២០១៣* |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ១១ | ១៦ | ២៤ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១១៦៣ | ១១៥២ | ៩៨០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១១ | ៦១ | ១៧ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ០ | ៧២ | ១២ |

➢**សំណង់** (ការអនុញ្ញាត) :

✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៧៥,៩ពាន់ម² ថយចុះ៣៦% ធៀបនឹងខែមុន និងថយចុះ១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១១១,៧លានដុល្លារ ថយចុះ៧៧% ធៀបនឹងខែមុន និងថយចុះ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន :

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² –ឧសភា ២០១៤ | ពាន់ម² –មេសា២០១៤ | ពាន់ម² –ឧសភា ២០១៣ |
|---|---|---|---|
| ▪ លំនៅឋាន | ៩១,៦ | ៣៤១,៨ | ២៦៩,០ |
| ▪ ឧស្សាហកម្ម | ២៤៨,១ | ៩៦,០ | ៦៣,០ |
| ▪ ទេសចរណ៍ | ២២,៣ | ១១,៤ | ៥,៧ |
| ... | | | |
| អនុញ្ញាតសរុប | ៣៧៥,៩ | ៥៩០,៦ | ៤២៤,១ |

✓ ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ ឧស្សាហកម្ម ៦៦% និងលំនៅឋាន ២៤%នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការទទួលបានការងារ

| ប្រភេទ | នាក់–ឧសភា ២០១៤ | នាក់–មេសា២០១៤ | នាក់–ឧសភា ២០១៣ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរ និងការងារ ) | NA | NA | NA |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៧០១៩ | ២១៤៨ | ២០៤៦ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៤២៣១ | ១២២៣ | ១១៣៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៧៨៨ | ៩២៥ | ៩០៨ |

➢ **វិនិយោគ**

តារាង៤.៤. គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ឧសភា២០១៤ | មេសា២០១៤ | ឧសភា២០១៣ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២១១,៦ | ៧៤,៥ | ៧៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១២,៥ | ១៩,៩ | ៥៧ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១០៣,៩ (១៧,១) | ៥៤,៦ (៣៣,២) | ១៦ (០) |
| វិស័យទេសចរណ៍ | ១៥,៤ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៧៩,៨ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២០ | ១៣ | ៧ |
| បង្កើតការងារ (ពាន់នាក់) | ២២,៦ | ៩,២ | ៤ |

➢ **សេវាកម្ម**

តារាង៤.៥. ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —ឧសភា ២០១៤ | ចំនួន — មេសា ២០១៤ | ចំនួន—ឧសភា២០១៣ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣០១ | ៣០៩ | ២២៨ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤ | ៤ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | NA | NA | NA |

➢ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៥កំពង់ផែ) មានចំនួន ៧៨៤,១ពាន់តោន កើនឡើង ៤% ធៀបនឹងខែមុន និងកើនឡើង ៤៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៤.៦. ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: -១៣% | (+២៥%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: -៧% | (+៨២%) |
| ▪ កំពង់ផែកំពង់សោម: +៩% | (+៤៨%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +២៧% | (+១៥%) |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

តារាង៤.៧.

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៩,៨ | -៤០% | +២៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៩,០ | -១១,៩% | +៤១,៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៣៩,២ | -១២% | +៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៨៤,៤ | -៧,១% | +០,៨% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ២៨៧,៧ | -១៣,៥% | -១,៥% |
| ✓ តាមផ្លូវអាកាស | ១២៦,៣ | -២១,៧% | ០ |
| ✓ តាមផ្លូវគោក និងទឹក | ១៦១,៤ | -៥,៨% | -២,៧% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ ពីប្រភពអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែឧសភាមានចំនួន ៣៥០៨,៤ពាន់លានរៀល (ស្មើនឹង ៨៧៧លានដុល្លារ ស.រ.អា.) កើនឡើង៤,៣% ធៀបនឹងខែមុន និងកើនឡើង១០,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១. បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១,៨% | +៥,០% | រថយន្តសរុប (ព.ល.រ) | -៣,០% | +៥,៤% |
| ប្រេងម៉ាស៊ូត | -៨,៨% | +២,២% | រថយន្តសរុប (គ្រឿង) | +៩,៣% | -០,៨% |
| ឧស្ម័ន | +៨៨១,៨% | -៣០,៥% | ត្រាក់ទ័រនិងគោយន្ត (គ្រឿង) | +១៧,៣% | +១៨,១% |
| អគ្គិសនីនាំចូល | | | ម៉ូតូ (គ្រឿង) | +៥,២% | +១៦,៥% |
| ដែកសំណង់ | +៤,២% | +៨០,៩% | អង្ករ | -៥៧,៩% | -៨៤,៥% |
| ស៊ីម៉ង់ត៍ | +២៩,១% | +៣៣,៤% | ផ្លែឈើនិងបន្លែ | +៣,៣% | +១៤១,០% |
| គ្រឿងអេឡិចត្រូនិក | +៤១,៤% | +២៤១,៣% | ជីនិងថ្នាំកសិកម្ម | +៧០,៣% | +៥,៥% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៧១,២% | -៦៥,៩% |

➡ **ការនាំចេញ** ខែឧសភាឆ្នាំ២០១៤ មានចំនួន ២៦៧៧,៧ពាន់លានរៀល ស្មើនឹង ៦៦៩,៤លានដុល្លារ ស.រ.អា. (៧៦% នៃការនាំចូល) កើនឡើង៣៤,០% ធៀបនឹងខែមុន និងកើនឡើង១៨,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២. បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៧៤,១% | +២៧៣,៣% | ផលិតផលនេសាទ | -០,២% | -៧០,២% |
| វាយនភណ្ឌនិងស្បែកជើង | +៣៨,៤% | +១៥,១% | កៅស៊ូ | +៨៨,៨% | +៣០,០% |
| អង្ករ | -០,៣% | +០,១% | | | |

➡ ក្នុងខែឧសភានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៨៣០,៧ពាន់លានរៀល ស្មើនឹង ២០៨លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភា ឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម :

**តារាង ៦.១.** សូចនាករសេដ្ឋកិច្ច សង្គមកិច្ច ដែលមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលថវិកាជាតិ | -២៨,១% | -៩,៧% | — |
| ២ | ចំណាយថវិកាជាតិ | -៤៣,៦% | -៤៧,៦% | — |
| ៣ | សំណង់អនុញ្ញាតឲ្យសាងសង់ (ម²) | -៣៦% | -១១% | — |
| ៤ | ចំនួនទេសចរមកទស្សនាកម្ពុជា | -១៣,៥% | -១,៥% | — |

## ៧) ស្មារតីអង្គប្រជុំ

អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម :

១) គួរកត់សម្គាល់មុខទំនិញមួយចំនួនដែលមានការឡើងថ្លៃខ្ពស់ដូចជា សាច់ជ្រូក ផ្លែឈើ និងឧស្ម័ន។

២) កម្រិតដុល្លាររូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជា មាននិន្នាការកើនឡើង។

៣) ចំណូលថវិកាជាតិក្នុងខែឧសភាមានការធ្លាក់ចុះ ដោយសារចំណូលពន្ធមួយចំនួន ដូចជាពន្ធលើប្រាក់ចំណេញ និងថវិការាជធានី-ខេត្ត ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៦/១៤ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមីទិញអបអរសាទរខួបលើកទី៦៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ ២០១៤ ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ។ |
| ២ | ០២/០៦/១៤ ម៉ោង ០៩:០០នាទី | បន្តដឹកនាំកិច្ចប្រជុំចង្អៀតលើកទី៤ ដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៣/០៦/១៤ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីទទួលជាផ្លូវការនូវទេវរូបចំនួន០៣អង្គ ដែលត្រូវបានបញ្ជូនត្រឡប់មកពីសហរដ្ឋអាមេរិក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៥/០៦/១៤ ម៉ោង ១០:០០នាទី | ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim អ្នកគ្រប់គ្រងក្រុមហ៊ុនម៉ាន់ស៊ូដេញ្ជូតិច នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/០៦/១៤ ម៉ោង ១៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពិសាភោជនាហារពេលល្ងាច ជាមួយនឹងការប្រគុំតន្ត្រី នៅស្ពានទូតអាល្លឺម៉ង់។ |
| ៦ | ០៧/០៦/១៤ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលាគរុកោសល្យភូមិភាគខេត្តតាកែវ។ |
| ៧ | ០៩/០៦/១៤ ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Greenville ដើម្បីសិក្សាប្លង់ Parking នៅ Welcome Center នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ០៩/០៦/១៤ ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មួក និងសញ្ញា មជ្ឈមណ្ឌលមាត្រាសាស្ត្រ ជាតិ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៤ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ១០/០៦/១៤<br>ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីត្រួតពិនិត្យលើគម្រោងសាងសង់ចំណតរថយន្ត ផ្លូវដើរ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានាក្នុងមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១០/០៦/១៤<br>ម៉ោង ១៦:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក Jean MOREL នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១១/០៦/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ប្រាក់រង្វាន់ជ័យលាភីជូនដល់ប្រតិភូកីឡាករ និងកីឡាការិនី ដែលបានចូលរួមការប្រកួតអាស៊ានប៉ារ៉ាហ្គេមលើកទី៧នៅប្រទេសមីយ៉ាន់ម៉ា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១២/០៦/១៤<br>ម៉ោង ១០:០០នាទី | រាយការណ៍ស្តីពីការងារប្លង់សាងសង់ Parking នៅ Welcome Center ជូនឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ១៣ | ១២/០៦/១៤<br>ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **សយ សុខាន់** និងឯកឧត្តម **ផែន សុវិជ្ជានោ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៦/០៦/១៤<br>ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារដែលពាក់ព័ន្ធទៅនឹងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាមួយឯកឧត្តម **ផែន សុវិជ្ជានោ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៣/០៦/១៤<br>ម៉ោង ១០:០០នាទី | ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim អ្នកគ្រប់គ្រងក្រុមហ៊ុនម៉ាន់ស៊ូដេញ្ញូតិច នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៣/០៦/១៤<br>ម៉ោង ១៦:០០នាទី | ដឹកនាំកិច្ចប្រជុំការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៤/០៦/១៤<br>ម៉ោង ០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌។<br>៤-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | ២៤/០៦/១៤<br>ម៉ោង ១៧:០០នាទី | បន្តដឹកនាំកិច្ចប្រជុំការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ២៥/០៦/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌។<br>៤-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២៦/០៦/១៤<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | ២៦/០៦/១៤<br>ម៉ោង ១៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកួតកីឡាប្រដាល់ក្បាច់គុណបុរាណខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីលានទាត់បាល់សាលាគរុកោសល្យភូមិភាគខេត្តតាកែវ។ |
| ២២ | ២៧/០៦/១៤<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសិក្ខាសាលាថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក (APR) "ការគាំទ្ររបស់មនុស្សពេញវ័យ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកាយរិទ្ធជាតិកម្ពុជា និងលោកជំទាវ នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៨/០៦/១៤<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងមីទិញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៣ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងលោកជំទាវ នៅបរិវេណមុខទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជាខេត្តតាកែវ។ |
| ២៤ | ៣០/០៦/១៤<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ភោធជាផ្លូវការផ្សារទំនើប អ៊ីអន ម៉ល ភ្នំពេញ របស់ក្រុមហ៊ុនអ៊ីអន ម៉ល (ខេមបូឌា) ខូអិលធីឌី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in